# ខ្លឹមសារសង្ខេបសាលក្រមតុលាការយុត្តិធម៌អឺរ៉ុប

L'Oreal SA v. Ebay ( UK ).., Case C-324/09, 12 July 2011

**ពាក្យគន្លឹះ៖** ម៉ាកពាណិជ្ជកម្ម (Trade Mark :TM), ការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាកម្មអ៊ីនធរណែត (ISP), ការការពារអតិថិជន, ដីកាបញ្ជា (injunction), ការការពារទិន្នន័យ, កម្មសិទ្ធិបញ្ញា, ផលិតផលក្លែងក្លាយ

## ១. ប្រវត្តិនីតិវិធី

L'Oreal ជាក្រុមហ៊ុនផលិត ផលិតផលមួយចំនួន ដូចជាគ្រឿងសំអាង បានចុះបញ្ជី TM នៅក្នុងប្រទេសអង់គ្លេស និងស្ថិតនៅក្នុងសមាគម TM អឺរ៉ុប (community trade mark)។ Ebay ជាក្រុមហ៊ុនផ្តល់សេវាលក់ផលិតផលអនឡាញ ចាត់ចែង (operator) ដាក់ឲ្យគេលក់ផលិតផលលើគេហទំព័រ www.ebay.co.uk របស់ខ្លួន។ ក្រុមហ៊ុន បានឲ្យតម្រូវឲ្យអ្នកលក់ធ្វើកិច្ចព្រមព្រៀង មិនដាក់លក់នូវផលិតផលក្លែងក្លាយ និងបង្កើត VeRO (verified Rights Owner) ដែលម្ចាស់ TM អាចផ្តល់យោបល់។ ទោះបីជាយ៉ាងនេះក្តី L'Oreal មិនបានចូលរួមទេ (កថា.៤៦)។

មានផលិតផលចំនួន១៧មុខ ដែលដាក់លក់លើអនឡាញ សម្រាប់លក់ទៅ North America និងមួយចំនួនមានទីតាំងនៅហុងកុង។ ផលិតផលខ្លះ ត្រូវបានដាក់លក់ដោយគ្មានស្រោម និងខ្លះសម្រាប់សាកល្បង (កថា. ៤៩)។ ក្នុងចំណោម ១៧ មាន ២ មុខដែលមានបញ្ហា ដោយសារដាក់លក់ក្រោម TM របស់ L'Oreal ដោយគ្មានអនុញ្ញាត ហើយ Ebay បានប្រើប្រាស់សញ្ញាស្រដៀងនឹង TM សម្រាប់ស្រាវជ្រាវលើ google.com (sponsored link) ដើម្បីចូលទៅកាន់គេហទំព័រ Ebay។ ក្នុងពេលខ្លះ Ebay បានផ្សាយពាណិជ្ជកម្មលក់ដោយខ្លួនឯងដែរ។

L'Oreal បានប្តឹងទៅតុលាការអង់គ្លេស ស្នើសុំឲ្យចេញវិធានការលើ Ebay និងទាមទារសំណង។ តុលាការជាន់ខ្ពស់ប្រទេសនេះ បានសម្រេចក្នុងថ្ងៃទី ២២ ឧសភា ឆ្នាំ ២០០៩ (កថា. ៤៥) និងបានបញ្ជូនមកតុលាការយុត្តិធម៌អឺរ៉ុប ដើម្បីសម្រេចលើបញ្ហាច្បាប់មួយចំនួន ទាក់ទងនឹងការបកស្រាយបទបញ្ជា (Directives) របស់សហគមន៍អឺរ៉ុប។ តុលាការនេះ បានសម្រេចពេញអង្គ (grand chamber) និងចេញសេចក្តីសម្រេចក្នុងថ្ងៃទី ១២ កក្កដា ២០១១។

## ២. វិធានអនុវត្ត

មានលិខិតបទដ្ឋានជាច្រើន ដែលតុលាការ យកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចៈ ១. សេចក្តីណែនាំលេខ៨៩/១០៤ និង បទប្បញ្ញត្តិលេខ៤០/៩៤ ទាក់ទងម៉ាកពាណិជ្ជកម្ម, ២. សេចក្តីណែនាំលេខ ២០០០/៣១ ស្តីពីសេវាព័ត៌មានសង្គម, ៣. សេចក្តីណែនាំលេខ២០០៤/៤៨ ស្តីពីការអនុវត្តកម្មសិទ្ធិបញ្ញា, និង ៤. សេចក្តីណែនាំលេខ៧៦/៧៦៨ ស្តីពីផលិតផលកែសម្ផស្ស។

## ៣. សម្អាងហេតុ និងខ្លឹមសារសម្រេច

១. ម្ចាស់ម៉ាក អាចរារាំងមិនឲ្យលក់ ឬស្នើលក់ ឬផ្សាយពាណិជ្ជនូវផលិតផល ដែលមានម៉ាកចុះបញ្ជីសហគមអឺរ៉ុប ឬសហគម TM ទោះទំនិញនោះស្ថិតនៅក្នុងរដ្ឋទីបី មិនទាន់បានដាក់លក់លើទីផ្សារ និងលក់លើទីផ្សារអនឡាញ ដោយគ្មានការអនុញ្ញាតពីម្ចាស់។

២. ការផ្តល់ចំនួនតិចតួច ជាគម្រូដោយមិនគិតថ្លៃនូវផលិតផលចុះម៉ាក ដល់អតិថិជន ដោយអ្នកចែកចាយ ដែលត្រូវបានអនុញ្ញាត (authorized distributors) មានន័យថា មិនមែនជាការដាក់លក់លើទីផ្សារទេ។

៣. ម្ចាស់ម៉ាក មានសិទ្ធិផ្តាច់មុខ និងអាចជំទាស់ការលក់នូវផលិតផលគ្មានស្រោម/ប្រអប់ ដែលបានដកព័ត៌មានចម្បងចេញ ឬប្រសិនបើការដកចេញ មិនប៉ះពាល់ព័ត៌មានចម្បងដែលតម្រូវឲ្យមាន ក៏ម្ចាស់ម៉ាក មានសិទ្ធិជំទាស់ការលក់ឡើងវិញ បើការដកព័ត៌មាននោះ ប៉ះដល់កិត្តិយសនៃម្ចាស់ម៉ាក។

៤. ម្ចាស់ម៉ាក មានសិទ្ធិបង្ការមិនឲ្យ អ្នកចាត់ចែងលក់អនឡាញ (online marketplace operator) ផ្សាយពាណិជ្ជកម្មនូវទំនិញមានម៉ាក សម្រាប់លក់ បើការផ្សាយនោះ មិនបានជួយដល់អ្នកប្រើអីនធរណែត ឲ្យយល់ច្បាស់ថាទំនិញនោះ មកពីម្ចាស់ម៉ាក ឬតតិយជន ឬ អ្នកមានទំនាក់ទំនងសេដ្ឋកិច្ចជាមួយម្ចាស់ម៉ាក។

៥. តុលាការ បានបង្ហាញ អ្វីទៅជាអ្នកចាត់ចែងដែលដើរតួសំខាន់ គឺពួកគេបានដឹងអំពីការគ្រប់គ្រងទិន្នន័យដែលបានផ្ទុក (stored)។ ទោះបីមិនបានដើរតួសំខាន់ ក៏ Operator នៅតែមិនរួចពីការទទួលខុសត្រូវ បើដឹងថា សំណើសម្រាប់លក់នោះ ខុសច្បាប់ ហើយខកខានចាត់វិធានការបន្ទាន់។

៦. តុលាការ អះអាងថា បទប្បញ្ញត្តិនៃសហគមអឺរ៉ុប តម្រូវឲ្យតុលាការជាតិ ចាត់វិធានការការពារកម្មសិទ្ធិបញ្ញា ដោយបញ្ជាឲ្យទីផ្សារអនឡាញ ចាត់វិធានការ មិនគ្រាន់តែបញ្ឈប់ការបំពានទេ ថែមទាំង

បង្កាការបំពានទាពេលអនាគត។ វិធានការនេះ ត្រូវមានប្រសិទ្ធភាព សមាមាត្រ និងមិនបង្កជារបាំងមិនសមស្របដល់ពាណិជ្ជកម្ម។

## ៤. ខ្លឹមសារដកស្រង់

ម៉ាកពាណិជ្ជកម្ម មានតួនាទីជាចម្បង ក្នុងការផ្តល់ដល់អ្នកប្រើប្រាស់ ជាមួយការធានាថា អត្តសញ្ញាណប្រភពនៃផលិតផល សេវាកម្ម ជាពិសេស ដើម្បីធានាថា ទំនិញទាំងអស់មានម៉ាក ដែលត្រូវបានផលិត ឬចែកចាយ ក្រោមការគ្រប់គ្រង នៃការផលិតទាំងស្រុង រួមចំណែកលើគុណភាព (កថា.៨០)។

In the second place, a trade mark, the essential function of which is to provide the consumer with an assurance as to the identity of the product’s origin, serves in particular to guarantee that all the goods bearing the mark have been manufactured or supplied under the control of a single undertaking which is responsible for their quality (see, inter alia, Case C-206/01 Arsenal Football Club [2002] ECR I-10273, paragraph 48, and Case C-59/08 Copad [2009] ECR I-3421, paragraph 45).

### សម្រាប់អត្ថបទនៃសេចក្តីសម្រេចទាំងស្រុងសូមចូលទៅកាន់គេហទំព័រ៖

http://www.measboralaws.com/images/pdf/verdict/a02957c720277cc71b4ac640bdf272b1.pdf